**សម្តេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកទុក្ខ

## ជូន

## ឯកឧត្តម ម៉ុក ម៉ារ៉េត សមាជិករដ្ឋសភា
## និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តតាកែវ ព្រមទាំងក្រុមគ្រួសារ

**ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន!**

ខ្ញុំនិងភរិយា មានសេចក្តីក្រៀមក្រំជាខ្លាំង និងសោកស្តាយឥតឧបមា ដោយទទួលដំណឹងថា **លោកជំទាវ មហាឧបាសិកា ឈា ឡាង** ជាភរិយារបស់ឯកឧត្តមបានទទួលមរណភាព នៅថ្ងៃសៅរ៍ ៧កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង១១:៤៥នាទី នៅទីក្រុងប៉ារីស ប្រទេសបារាំង ត្រូវនឹងម៉ោង១៦:៤៤នាទី នៅរាជធានីភ្នំពេញ ក្នុងជន្មាយុ៧០ឆ្នាំ ដោយរោគាពាធ។

ខ្ញុំសូមចូលរួមរំលែកទុក្ខជាមួយ**ឯកឧត្តម** និងក្រុមគ្រួសារ ចំពោះមរណភាព **លោកជំទាវ មហាឧបាសិកា ឈា ឡាង** ជាភរិយា ជាម្តាយ ជាម្តាយក្មេក ជាជីដូន ប្រកបដោយសង្គហធម៌ដ៏ប្រពៃ ព្រហ្មវិហារធម៌មិនចេះរីងស្ងួត និងជាអ្នកហ៊ានធ្វើពលិកម្មសព្វបែបយ៉ាង ដើម្បីរួមដំណើរគាំពារ ជ្រោមជ្រែងដល់**ឯកឧត្តម** ក្នុងការចូលរួមបម្រើជាតិ មាតុភូមិ និងរួមចំណែកក្នុងការកសាង និងអភិវឌ្ឍជាតិឱ្យមានការរីកចម្រើនជារៀងរហូតមក។ ទោះបីរូបកាយរបស់**លោកជំទាវ** បាត់បង់ទៅមែនពិត ប៉ុន្តែបានបន្សល់ទុកនូវអំពើជាកុសល កិត្តិយស សេចក្តីថ្លៃថ្នូរ ភាពតស៊ូអំណត់ព្យាយាម នឹងនៅស្ថិតស្ថិរជានិច្ចនិរន្តរ៍នៅក្នុងសន្តានចិត្តស្វាមី កូនចៅប្រុសស្រី និងញាតិមិត្តជិតឆ្ងាយទាំងអស់។

ខ្ញុំនិងភរិយា សូមឧទ្ទិសបួងសួងដល់វត្ថុសក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធ **លោកជំទាវ មហាឧបាសិកា ឈា ឡាង** ឆាប់បានទៅកាន់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ទទួលនូវសេចក្តីរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

ថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**